ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel + 63 2 632 4444
Fax + 63 2 636 4444

www.adb.org

NEWS RELEASE

# ធនាគារអភិវឌ្ឍន៍អាស៊ីមើលឃើញពីសក្តានុពលកំណើនខ្ពស់ ជាងមុនសម្រាប់ប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី

ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១៧) — សក្តានុពលកំណើនសេដ្ឋកិច្ចនៅតាមប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីសម្រាប់ឆ្នាំ ២០១៧ នេះ មានភាពល្អប្រសើរជាងមុន ដោយសារតែមានតម្រូវការនាំចេញខ្ពស់ជាងការរំពឹងទុកនៅក្នុងត្រីមាសទី ១ នៃឆ្នាំនេះ នេះបើតាមរបាយការណ៍ថ្មីមួយដែលចេញផ្សាយដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

ជាការបំពេញបន្ថែមលើរបាយការណ៍ *ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី ២០១៧* របស់ខ្លួន ADB បានបង្កើនសក្តានុពលកំណើនសម្រាប់តំបន់ ពី ៥,៧% ទៅ ៥,៩% សម្រាប់ឆ្នាំ ២០១៧ និង ពី ៥,៧% ទៅ ៥,៨% សម្រាប់ឆ្នាំ ២០១៨។ ការបង្កើនត្រឹមកម្រិតតិចតួចសម្រាប់អត្រានៅក្នុងឆ្នាំ ២០១៨ បែបនេះ ឆ្លុះបញ្ចាំងពីទស្សនៈបែបប្រយ័ត្នប្រយែងជុំវិញនិរន្តរភាពនៃកំណើនការនាំចេញខាងលើ។

លោក Yasuyuki Sawada ប្រធានសេដ្ឋវិទូរបស់ ADB បានមានប្រសាសន៍ថា "ប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ចាប់ផ្តើមចេញដំណើរបានយ៉ាងល្អនៅឆ្នាំនេះ ជាមួយនឹងកំណើននៃការនាំចេញ ដែលនាំឱ្យសក្តានុពលកំណើនជារួមមានការកើនឡើង សម្រាប់រយៈពេលដែលនៅសេសសល់ក្នុងឆ្នាំ ២០១៧។ បើទោះបីជាមានភាពមិនប្រាកដប្រជាជុំវិញភាពមាំមួននៃការងើបឡើងវិញរបស់សេដ្ឋកិច្ចសកលលោកក៏ដោយ យើងគិតថាសេដ្ឋកិច្ចរបស់តំបន់នេះ គឺស្ថិតនៅក្នុងស្ថានភាពមួយដ៏ល្អប្រសើរ សម្រាប់ទប់ទល់ជាមួយនឹងវិបត្តិនានាដែលអាចកើតមានឡើង ដែលអាចបង្កផលប៉ះពាល់ដល់ទស្សនវិស័យនៃតំបន់នេះ"។

កំណើនរួមគ្នានៃបណ្តាប្រទេសដែលមានសេដ្ឋកិច្ចឧស្សាហកម្មធំៗ ត្រូវបានព្យាករណ៍ថា នឹងនៅបន្តក្នុងកម្រិត ១,៩% ក្នុងឆ្នាំ ២០១៧ និង ២០១៨។ តួលេខព្យាករណ៍សម្រាប់ប្រទេសដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ប្រាក់អឺរ៉ូ និងប្រទេសជប៉ុនកើនឡើងខ្ពស់ជាងមុន ដោយសារតែតម្រូវការក្នុងស្រុកខ្ពស់

**Media Inquiries**

Erik Churchill
Tel: (632) 6831905
Mob: (63) 999 999 1905
E-mail: echurchill@adb.org

អាចទូទាត់ជាមួយនឹងការថមថយតិចតួចនៃកំណើនក្នុងសហរដ្ឋអាមេរិក ឲ្យមកនៅត្រឹម ២,២% បើធៀបការព្យាករណ៍កន្លងមក ២,៤% ដោយសារតែលទ្ធផលក្នុងត្រីមាសទី ១ នៃឆ្នាំ ២០១៧ មិនបានសម្រេចដល់កម្រិតជាទីគាប់ចិត្ត។

បើបែងចែកទៅតាមតំបន់ កំណើនសម្រាប់អាស៊ីបូព៌ា ត្រូវបានកែសម្រួលឡើងដល់ ៦,០% ក្នុងឆ្នាំ ២០១៧ និង ៥,៧% ក្នុងឆ្នាំ ២០១៨ បើធៀបនឹងការព្យាករដំបូងៗ ត្រឹម ៥,៨% និង ៥,៦%។ បន្ទាប់ពីមានការកើនឡើងតិចតួចកាលពីពេលថ្មីៗនេះ កំណើនការនាំចេញសុទ្ធ និងកំណើននៃការប្រើប្រាស់ក្នុងស្រុក បានជួយឲ្យសក្តានុពលកំណើននៅក្នុងប្រទេសចិនមានការកើនឡើង។ ឥឡូវនេះ ប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេលំដាប់ទី ២ ក្នុងសកលលោកមួយនេះ នឹងមានកំណើន ៦,៧% ក្នុងឆ្នាំ ២០១៧ និង ៦,៤% ក្នុងឆ្នាំ ២០១៨។

អាស៊ីខាងត្បូងនៅតែជាអនុតំបន់ដែលមានកំណើនឆាប់រហ័សជាងគេ ក្នុងចំណោមអនុតំបន់ទាំងអស់នៅអាស៊ី និងប៉ាស៊ីហ្វិក ដោយកំណើននឹងអាចសម្រេចទៅតាមការព្យាករដំបូងៗ ពោលគឺ ៧,០% ក្នុងឆ្នាំ ២០១៧ និង ៧,២% ក្នុងឆ្នាំ ២០១៨ នេះបើតាមការលើកឡើងនៅក្នុងរបាយការណ៍នេះ។ ប្រទេសឥណ្ឌាដែលជាប្រទេសមានសេដ្ឋកិច្ចធំជាងគេរបស់អនុតំបន់នេះ នឹងអាចសម្រេចទៅតាមការព្យាករកំណើនដែលត្រូវបានធ្វើកន្លងមក ពោលគឺ ៧,៤% ក្នុងឆ្នាំ ២០១៧ និង ៧,៦% ក្នុងឆ្នាំ ២០១៨ ដោយសារតែការប្រើប្រាស់ក្នុងប្រទេសមានកម្រិតខ្ពស់។

ការព្យាករកំណើនសម្រាប់អាស៊ីអាគ្នេយ៍គឺនៅដដែល ពោលគឺ ៤,៨% ក្នុងឆ្នាំ ២០១៧ និង ៥,០% ក្នុងឆ្នាំ ២០១៨ ជាមួយនឹងកំណើនកាន់តែឆាប់ជាងមុនសម្រាប់ប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងសិង្ហបុរី បើទោះបីជានិន្នាការនេះ មានការថមថយតិចតួច ដោយសារតែប្រទេសប្រ៊ុយណេមានកំណើនយឺតជាងការរំពឹងទុកក៏ដោយ។ របាយការណ៍នេះលើកឡើងថា តម្រូវការក្នុងស្រុកខ្ពស់ ជាពិសេស ការប្រើប្រាស់ជាលក្ខណៈឯកជន និងការវិនិយោគ នឹងបន្តជួយគាំទ្រដល់កំណើននៅក្នុងអនុតំបន់នេះ។

ទស្សនវិស័យសម្រាប់អាស៊ីកណ្តាលនៅឆ្នាំនេះ ក៏មានភាពល្អប្រសើរជាងមុនផងដែរ ដោយសារតែតម្រូវការក្នុងស្រុក និងការនាំចេញខ្ពស់នៅតាមប្រទេសមួយចំនួន បានធ្វើឲ្យសេដ្ឋកិច្ចរបស់អនុតំបន់នេះអាចងើបឡើងវិញបានយ៉ាងឆាប់រហ័ស ផ្ទុយទៅនឹងការរំពឹងទុកកន្លងមក។ គេរំពឹងថាកំណើននេះនឹងកើនឡើងដល់ ៣,២% ក្នុងឆ្នាំ ២០១៧ និង ៣,៨% ក្នុងឆ្នាំ ២០១៨ បើធៀបនឹង ៣,១% និង ៣,៥% នៅក្នុងការព្យាករកន្លងមក។

កំណើននៅតំបន់ប៉ាស៊ីហ្វិកនឹងនៅបន្តក្នុងអត្រាដដែល ពោលគឺ ២,៩% ក្នុងឆ្នាំ ២០១៧ និង ៣,៣% ក្នុងឆ្នាំ ២០១៨ ដោយសារតែប្រទេសប៉ាពួញូហ្គីនី ដែលជាប្រទេសមានសេដ្ឋកិច្ចធំជាងគេរបស់អនុតំបន់នេះ បន្តធូរស្រាលមកវិញជាបណ្តើរ ដោយសារតែការងើបឡើងវិញនូវឧស្សាហកម្មរ៉ែ និងវិស័យកសិកម្មរបស់ប្រទេសនេះ។ គេក៏រំពឹងផងដែរថា សក្តានុពលរឹងមាំក្នុងវិស័យទេសចរណ៍នឹងជួយជំរុញឲ្យអនុតំបន់នេះ មានកំណើនរឹតតែខ្ពស់បន្ថែមទៀត ជាពិសេសក្នុងប្រទេសហ្វូជី និងប្រទេសប៉ាឡាវ។

ក្នុងពេលជាមួយគ្នា មានការព្យាករណ៍ថា អតិផរណាតម្លៃទំនិញប្រើប្រាស់ក្នុងតំបន់នេះ នឹងមានកម្រិតទាបជាងការប៉ាន់ប្រមាណកាលពីលើកមុន ដោយសារតែតម្លៃប្រេង និងតម្លៃស្បៀងនៅលើទីផ្សារអន្តរជាតិនៅបន្តមានកម្រិតថេរ បើទោះបីជាមានការកើនឡើងនូវតម្រូវការក៏ដោយ នេះគឺដោយសារតែការផ្គត់ផ្គង់មានកម្រិតគ្រប់គ្រាន់ ហើយអាកាសធាតុមានលក្ខណៈអំណោយផល។ ឥឡូវនេះ គេរំពឹងថា អតិផរណាតម្លៃនឹងថយចុះមកនៅត្រឹម ២,៦% ក្នុងឆ្នាំ ២០១៧ និង ៣,០% ក្នុងឆ្នាំ ២០១៨ បើធៀបជាមួយនឹងការព្យាករណ៍ដំបូងៗ ៣,០% និង ៣,២%។

មានការិយាល័យកណ្តាលនៅទីក្រុងម៉ានីល ធនាគារអភិវឌ្ឍន៍អាស៊ីប្តេជ្ញាកាត់បន្ថយភាពក្រីក្រនៅអាស៊ី និងប៉ាស៊ីហ្វិច តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន កំណើនដែលធានាដល់ចីរភាពបរិស្ថាន និងសមាហរណកម្មតំបន់។ បង្កើតឡើងក្នុងឆ្នាំ ១៩៦៦ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងប្រារព្ធខួបលើកទី ៥០ នៃភាពជាដៃគូអភិវឌ្ឍន៍របស់ខ្លួនក្នុងតំបន់។ ធនាគារនេះជាកម្មសិទ្ធិរបស់សមាជិកចំនួន ៦៧ ប្រទេស ដែលក្នុងនោះ ៤៨ ប្រទេស មកពីតំបន់នេះ។ ក្នុងឆ្នាំ ២០១៦ ជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានចំនួនសរុប ៣១,៧ ពាន់លានដុល្លារ ក្នុងនោះមានសហហិរញ្ញប្បទានចំនួន ១៤ ពាន់លានដុល្លារ។